ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៦៣ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងាររបស់រាជរដ្ឋាភិបាលដើម្បីសម្របសម្រួលដោះស្រាយសំណើ និងសំណូមពររបស់អង្គការសង្គមស៊ីវិល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨១៥/០១០ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតក្រុមការងាររបស់រាជរដ្ឋាភិបាលដើម្បីសម្របសម្រួលដោះស្រាយសំណើ និងសំណូមពររបស់អង្គការសង្គមស៊ីវិល ដែលមានសមាសភាពដូចខាងក្រោម៖

១. ឯកឧត្តម **ឌី សុគុដាន** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ប្រធាន

២. រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ អនុប្រធាន
៣. ឯកឧត្តម **សួស ច្រាន់ថា** អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ អនុប្រធានប្រចាំការ
៤. តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក
៥. តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក
៦. តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក
៧. តំណាងក្រសួងយុត្តិធម៌ សមាជិក
៨. តំណាងក្រសួងព័ត៌មាន សមាជិក
៩. តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក
១០. តំណាងក្រសួងបរិស្ថាន សមាជិក
១១. តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក
១២. តំណាងធនាគារជាតិ នៃកម្ពុជា សមាជិក
១៣. តំណាងអគ្គនាយកដ្ឋានពន្ធដារ សមាជិក
១៤. តំណាងនិយ័តករគណនេយ្យ និងសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ សមាជិក
១៥. តំណាងអគ្គស្នងការដ្ឋាននគរបាលជាតិ សមាជិក
១៦. តំណាងក្រុមប្រឹក្សានីតិកម្ម នៃក្រសួងមហាផ្ទៃ សមាជិក
១៧. ប្រធាននាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយ នៃក្រសួងមហាផ្ទៃ សមាជិក។

**ប្រការ២ .-**

ក្រុមការងារនេះមានភារកិច្ចដូចខាងក្រោម៖

- រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយអង្គការសង្គមស៊ីវិល ដើម្បីពិនិត្យពិភាក្សានូវបញ្ហាប្រឈមនានា ដែលសង្គមស៊ីវិលបានជួបប្រទះ
- ប្រមូលព័ត៌មាននិងសិក្សាអំពីសំណើនិងសំណូមពរផ្សេងៗរបស់អង្គការសង្គមស៊ីវិល រួចលើកយោបល់ជូនរាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីពិនិត្យដោះស្រាយជាសមត្ថកិច្ច
- ផ្សព្វផ្សាយនិងលើកកម្ពស់ការយល់ដឹងដល់អង្គការសង្គមស៊ីវិលនិងភាគីពាក់ព័ន្ធផ្សេងទៀតអំពីច្បាប់ស្ដីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ដែលពាក់ព័ន្ធនឹងអង្គការសង្គមស៊ីវិល
- បំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់ពីប្រមុខរាជរដ្ឋាភិបាល។

**ប្រការ៣ .-**

ក្រុមការងារនេះត្រូវបំពេញការងាររបស់ខ្លួនក្រោមការណែនាំ និងដឹកនាំផ្ទាល់ពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** ... 

**ប្រការ៤ .-**

ក្រុមការងារមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងមហាផ្ទៃក្នុងការបំពេញការងាររបស់ខ្លួន។ អនុប្រធាន និងសមាជិកក្រុមការងារត្រូវចូលរួមប្រជុំតាមការកោះអញ្ជើញរបស់ប្រធានក្រុមការងារ។ ក្រុមការងារមានសិទ្ធិ ប្រើប្រាស់មន្ត្រីក្រោមឱវាទ ដើម្បីជួយបំពេញការងារតាមការចាំបាច់។

**ប្រការ៥ .-**

សេចក្តីសម្រេចលេខ៨៤ សសរ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់រាជរដ្ឋាភិបាលកម្ពុជា សេចក្តី សម្រេចលេខ២៤ សសរ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២០ របស់រាជរដ្ឋាភិបាលកម្ពុជា និងបទប្បញ្ញត្តិទាំង ឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហ ប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័ន ដែល ពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ២ កើត ខែ កត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល÷**

- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចធិបតីនាយករដ្ឋមន្ត្រី
- ដូចប្រការ៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ